# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ២៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតគណៈកម្មាធិការរៀបចំឯកសារសម្រាប់ការត្រួតពិនិត្យ គោលនយោបាយពាណិជ្ជកម្មកម្ពុជាក្រោមក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០៤/០០២ ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារនៃការចូលរួមរបស់ព្រះរាជាណាចក្រកម្ពុជាក្នុងអង្គការពាណិជ្ជកម្មពិភពលោក
- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ត្រូវបានបង្កើតគណៈកម្មាធិការរៀបចំឯកសារសម្រាប់ការត្រួតពិនិត្យគោលនយោបាយពាណិជ្ជកម្មកម្ពុជាក្រោមក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក ដែលសរសេរជាអក្សរកាត់ថា **គ.ត.ព.** ក្នុងគោលបំណងដើម្បីរៀបចំឯកសារសម្រាប់ការត្រួតពិនិត្យគោលនយោបាយពាណិជ្ជកម្មកម្ពុជា និងការអនុវត្តកាតព្វកិច្ចក្រោមក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក។

## ជំពូកទី២
## ភារកិច្ចរបស់ គ.ត.ព.

**មាត្រា២ .-**

**គ.ត.ព.** មានភារកិច្ចដូចតទៅ៖

- សម្របសម្រួលជាមួយបណ្ដាក្រសួង ស្ថាប័នពាក់ព័ន្ធ និងវិស័យឯកជន ដើម្បីរៀបចំឯកសារសម្រាប់ការត្រួតពិនិត្យគោលនយោបាយពាណិជ្ជកម្មកម្ពុជា និងការអនុវត្តកាតព្វកិច្ចក្រោមក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក
- ពិនិត្យនិងលើកយោបល់ជូនរាជរដ្ឋាភិបាល ដើម្បីកែសម្រួលលិខិតបទដ្ឋានគតិយុត្តនិងគោលនយោបាយពាណិជ្ជកម្មកម្ពុជា ឱ្យមានសង្គតិភាពជាមួយនឹងវិធាននិងកិច្ចព្រមព្រៀងនៃអង្គការពាណិជ្ជកម្មពិភពលោក
- ពិនិត្យនិងធ្វើបច្ចុប្បន្នកម្មលើកម្មវិធីការងាររបស់រាជរដ្ឋាភិបាលសម្រាប់ការអនុវត្តកាតព្វកិច្ច និងការសន្យាក្រោមក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក
- កៀរគរការគាំទ្រពីដៃគូអភិវឌ្ឍនិងវិស័យឯកជន ក្នុងដំណើរការរៀបចំឯកសារនិងការចូលរួមកិច្ចប្រជុំនានា ការរៀបចំឬកែសម្រួលលិខិតបទដ្ឋានគតិយុត្តនិងគោលនយោបាយពាក់ព័ន្ធ
- រៀបចំរបាយការណ៍ស្ដីពីលទ្ធផលនៃកិច្ចប្រជុំការត្រួតពិនិត្យគោលនយោបាយពាណិជ្ជកម្មកម្ពុជា ជូនកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ដើម្បីជ្រាបនិងផ្ដល់អនុសាសន៍ណែនាំ
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីប្រមុខរាជរដ្ឋាភិបាល។

## ជំពូកទី៣
## សមាសភាពរបស់ គ.ត.ព.

**មាត្រា៣ .-**

**គ.ត.ព.** មានសមាសភាពដូចតទៅ៖

| | |
|---|---|
| - រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | ប្រធាន |
| - រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ១រូប | អនុប្រធានអចិន្ត្រៃយ៍ |
| - រដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី ១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងយុត្តិធម៌ ១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ១រូប | សមាជិក |
| - អគ្គទេសាភិបាលរងធនាគារជាតិនៃកម្ពុជា ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងបរិស្ថាន ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងរ៉ែនិងថាមពល ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងផែនការ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសុខាភិបាល ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន ១រូប | សមាជិក |

- អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក
- រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងព័ត៌មាន ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងទេសចរណ៍ ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ១រូប សមាជិក
- អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម មួយចំនួន សមាជិក
- អនុរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ១រូប សមាជិក
- អគ្គរាជទូត និងជាប្រធានស្ថានបេសកកម្មអចិន្ត្រៃយ៍នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំអង្គការពាណិជ្ជកម្មពិភពលោក និងអង្គការអន្តរជាតិពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស សមាជិក
- ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា សមាជិក។

សមាសភាពជាក់ស្តែងរបស់ **គ.ត.ព.** ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**គ.ត.ព.** អាចមានសមាសភាពបន្ថែមជាប្រធានស្ថាប័នឬតំណាងនៃក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀតក្នុងរាជរដ្ឋាភិបាលតាមការចាំបាច់។ សមាសភាពបន្ថែមត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

## ជំពូកទី៤
## ការប្រព្រឹត្តទៅរបស់ គ.ត.ព.

**មាត្រា៤ .–**

អនុប្រធាននិងសមាជិក **គ.ត.ព.** ត្រូវចូលរួមកិច្ចប្រជុំតាមការអញ្ជើញរបស់ប្រធាន **គ.ត.ព.** ឬតំណាងតាមការប្រគល់សិទ្ធិពីប្រធាន **គ.ត.ព.**។ ក្នុងករណីអវត្តមាន ប្រធាន **គ.ត.ព.** អាចប្រគល់សិទ្ធិជូនអនុប្រធានអចិន្ត្រៃយ៍ ឬអនុប្រធានផ្សេងទៀត ដឹកនាំកិច្ចប្រជុំជំនួស។

**មាត្រា៥ .–**

ប្រធាន **គ.ត.ព.** មានសិទ្ធិអញ្ជើញតំណាងក្រសួង ស្ថាប័នរាជរដ្ឋាភិបាលដែលពាក់ព័ន្ធ ចូលរួមកិច្ចប្រជុំតាមការចាំបាច់។

ប្រធាន **គ.ត.ព.** អាចអញ្ជើញដៃគូអភិវឌ្ឍ វិស័យឯកជន និងទីប្រឹក្សា ឬជំនាញការជាតិនិងអន្តរជាតិចូលរួមប្រជុំពិគ្រោះយោបល់តាមការចាំបាច់។

**មាត្រា៦ .–**

**គ.ត.ព.** មានសិទ្ធិប្រើត្រារបស់ក្រសួងពាណិជ្ជកម្មសម្រាប់ដំណើរការការងាររបស់ខ្លួន។

**មាត្រា៧ .–**

**គ.ត.ព.** មានលេខាធិការដ្ឋានមួយជាសេនាធិការដែលមានទីតាំងនៅក្រសួងពាណិជ្ជកម្ម។

លេខាធិការដ្ឋាន **គ.ត.ព.** ត្រូវដឹកនាំដោយប្រធាន១(មួយ)រូប មានអនុប្រធាន និងសមាជិកមួយចំនួនតាមការចាំបាច់ ដែលត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ត.ព.**។

តួនាទីនិងភារកិច្ចរបស់លេខាធិការដ្ឋាន **គ.ត.ព.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ត.ព.**។

ប្រធាន អនុប្រធាន និងសមាជិកនៃលេខាធិការដ្ឋាន **គ.ត.ព.** គឺជាមន្ត្រីក្របខ័ណ្ឌក្រសួងពាណិជ្ជកម្ម។

## ជំពូកទី៥
## ប្រភពធនធានរបស់ គ.ត.ព.

**មាត្រា៨ .-**

**គ.ត.ព.** មានប្រភពធនធានផ្គត់ផ្គង់ដោយថវិកាជាតិជាកញ្ចប់ថវិការបស់ក្រសួងពាណិជ្ជកម្ម។

**គ.ត.ព.** មានសិទ្ធិទទួលនិងចាត់ចែងប្រើប្រាស់ប្រភពធនធានស្របច្បាប់ផ្សេងៗតាមការកំណត់របស់ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមានសម្រាប់ដំណើរការការងាររបស់ខ្លួន។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា៩ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១០ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ១២ រោច ខែ បុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ កុម្ភៈ ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម និម្មល**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ